# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Mar-2013, 09:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## សេចក្ដីជំទាស់មិនទទួលយកឯកសារថ្មី

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញាMathilde CHIFFERT

កញ្ញា អ៊ូច ស្រីផាត់

លោកPierre TOUCHE

កញ្ញាBlandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I-ការរំឭកនីតិវិធី

១. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានចេញដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ[1] អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង។

២. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសាររបស់ខ្លួនក្រោមទម្រង់ជាឧបសម្ព័ន្ធចំនួន ២១[2]។ ឧបសម្ព័ន្ធ ២១ មានចំណងជើងថា *"ឯកសារថ្មី"* ដែលក្នុងនោះមានឯកសារចំនួន៤៨១ ដែលមិនត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងស៊ើបអង្កេត។ កិច្ចពិភាក្សាដេញដោលផ្ទាល់មាត់ស្តីពីភាពអាចទទួលយកបាននៃឯកសាររបស់សហព្រះរាជអាជ្ញា ត្រូវបានធ្វើឡើង[3] ប៉ុន្តែ មិនបានផ្តោតលើ *"ឯកសារថ្មី"* ទាំងនេះទេ។ ជាក់ស្តែង អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា *"សេចក្តីណែនាំបន្ថែមពាក់ព័ន្ធនឹងការពិភាក្សាលើឯកសារថ្មីទាំងអស់ នឹងចេញនៅពេលសមស្របខាងមុខ"*[4]។

៣. នៅក្នុងសវនាការថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ លោកមេធាវី គង់ សំអុន បានកត់សម្គាល់ថា ឧបសម្ព័ន្ធ ២១ ប្រមូលផ្តុំគ្រប់ឯកសារថ្មីទាំងអស់ ដែលមានដាក់នៅក្នុងឧបសម្ព័ន្ធ ១ ដល់ ២១ របស់សហព្រះរាជអាជ្ញា។ ទោះជាយ៉ាងណា លោកបានបញ្ជាក់ថាលោកនឹងមិនពិនិត្យឯកសារថ្មី

---

[1] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9។

[2] បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការ ស្របតាមវិធាន ៨០(៣) ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/31 កថាខណ្ឌ ១។

[3] ប្រតិចារឹកសវនាការ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/28.1, ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/29.1, ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/30.1, ប្រតិចារឹកសវនាការ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/46.1, ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/47.1, ប្រតិចារឹកសវនាការ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/48.1, ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/49.1។

[4] បច្ចុប្បន្នភាពទៅលើអនុស្សរណៈស្តីពីសវនាការលើឯកសារនៅដំណាក់កាលបន្ទាប់ (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២) ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E172/5 កថាខណ្ឌ ៧។

ទាំងនេះនៅក្នុងសវនាការនេះទេ គឺលោកនឹងពិនិត្យនៅពេលក្រោយ ស្របតាមសេចក្ដីណែនាំរបស់អង្គជំនុំជម្រះ[5]។

៤. ទើបតែនៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ តាមរយៈអ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីដាក់សេចក្ដីជំទាស់ទៅនឹងឧបសម្ព័ន្ធ ២១ របស់សហព្រះរាជអាជ្ញា ក៏ដូចជាឯកសារថ្មីផ្សេងទៀតដែលភាគីផ្សេងទៀតបានដាក់[6]។ អង្គជំនុំជម្រះមិនបានកំណត់អត្ថសញ្ញាណ *"ឯកសារថ្មីផ្សេងទៀតរបស់ភាគី"* នោះទេ។

៥. ក៏ប៉ុន្តែ មេធាវីការពារក្ដីលោក ខៀវ សំផន កត់សម្គាល់ និងសម្ដែងនូវការសោកស្ដាយថា ទោះបីជាមិនទាន់បានឆ្លងកាត់ការពិភាក្សាដេញដោលតទល់គ្នាលើឯកសារថ្មីទាំងនេះក៏ដោយ ក៏ឯកសារថ្មីមួយចំនួនទទួលបានលេខសម្គាល់ E3 រួចទៅហើយ។

## II-ការកត់សម្គាល់បឋម

៦. ចាប់ពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ មក ការផ្លាស់ប្ដូរជាច្រើនពាក់ព័ន្ធនឹងកាលវិភាគសវនាការបានប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធភាពជាក់ស្ដែងរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ក្នុងការពិភាក្សាដេញដោលអំពីភាពអាចទទួលយកបាននៃឯកសារថ្មីទាំង ៤៨១ របស់សហព្រះរាជអាជ្ញា និង *"ឯកសារថ្មីផ្សេងទៀតរបស់ភាគី"*។

៧. នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានប្រកាសថានឹងស្ដាប់សក្ខីកម្មសាក្សីជំនាញ Elizabeth BECKER (TCE-80) នៅសប្ដាហ៍ចាប់ពីថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ តទៅ[7]។

---

[5] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/47.1 ទំព័រ ៤ បន្ទាត់ទី ៣ ដល់បន្ទាត់ទី ១៥។

[6] អ៊ីមែលរបស់លោកស្រី Susan LAMB ផ្ញើជូនភាគី នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៥ និង ២៣ នាទី កម្មវត្ថុ៖ *"ចម្លងជូនសម្រាប់ជាព័ត៌មានបឋម អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងបញ្ហាឯកសារផ្សេងៗ"*។ ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងសំណើផ្សេងៗមួយចំនួនពាក់ព័ន្ធនឹងឯកសារ និងពេលវេលាកំណត់ អនុស្សរណៈចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E246/1 កថាខណ្ឌ ៤ (អនុស្សរណៈត្រូវបានជូនដំណឹងជាភាសាខ្មែរ នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងជាភាសាបារាំង នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣)។

[7] ការកំណត់កាលបរិច្ឆេទស្ដាប់សក្ខីកម្មសាក្សី និងអ្នកជំនាញ សម្រាប់ដើមឆ្នាំ ២០១៣ អនុស្សរណៈចុះថ្ងៃទី ០៨ ខែ មករា

៨. នៅយប់ថ្ងៃ សុក្រ ទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ៨ និង ៤៥នាទី ភាគីទទួលបានការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានធ្វើមោឃភាពដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ("សេចក្ដីសម្រេចអំពីការបំបែកកិច្ចដំណើរការនីតិវិធី")[8]។

៩. បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ តំណាងមួយរូបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី បានផ្ញើអ៊ីម៉ែលទៅមន្ត្រីច្បាប់ជាន់ខ្ពស់ ដើម្បីសួរនាំអំពីផលវិបាកនៃសេចក្ដីសម្រេចនេះទៅលើការស្ដាប់សក្ខីកម្ម Elizabeth BECKER[9]។ នៅថ្ងៃដដែលនោះ មន្ត្រីច្បាប់ជាន់ខ្ពស់បានបញ្ជាក់ថាអង្គជំនុំជម្រះនឹងផ្ញើអនុស្សរណៈជូនភាគី នៅព្រឹកថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣[10]។

១០. នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានប្រកាសថា សវនាការពាក់ព័ន្ធនឹងផលវិបាកនៃសេចក្ដីសម្រេចអំពីការបំបែកកិច្ចដំណើរការនីតិវិធី នឹងគ្រោងរៀបចំ នៅថ្ងៃទី ១៤ និងថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ ហើយបានស្នើឲ្យភាគីឆ្លើយទៅនឹងសំណួរមួយចំនួន[11]។ អង្គជំនុំជម្រះក៏បាន

---

ឆ្នាំ ២០១៣ ឯកសារ E236/4 កថាខណ្ឌ ១។

[8] សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ/អ.ជ.ត.ក (១៨) *សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១* ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13។

[9] អ៊ីម៉ែលរបស់លោកស្រី Fernandez ផ្ញើជូនលោកស្រី Susan LAMB នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៥ និង ៣០ នាទី កម្មវត្ថុ៖ *"អ្នកជំនាញ TCE-80"*។

[10] អ៊ីម៉ែលរបស់លោកស្រី Susan LAMB ផ្ញើជូនលោកស្រី Fernandez នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៦ និង ០៦ នាទី កម្មវត្ថុ៖ *"ឆ្លើយតប៖ អ្នកជំនាញ TCE-80"*។

[11] អ៊ីម៉ែលរបស់លោកស្រី Susan LAMB ផ្ញើជូនភាគី នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១១ និង ៣៤ នាទី កម្មវត្ថុ៖ *"សេចក្ដីណែនាំដល់ភាគី មុនសវនាការពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើវិសាលភាពនៃការជំនុំជម្រះក្ដីនៃសំណុំរឿង ០០២/០១ (ថ្ងៃ ព្រហស្បតិ៍ ទី ១៤ និងថ្ងៃ សុក្រ ទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣)"* ដោយមានភ្ជាប់ការចម្លងជូនអនុស្សរណៈ *"សេចក្ដីណែនាំដល់ភាគីនានា ដោយសារតែមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពី វិសាលភាពនៃសំណុំរឿង ០០២/០១ (ឯកសារ E163/5/1/13)"*។

ជូនដំណឹងផងដែរថាសវនាការអាចនឹងបន្តដល់សប្តាហ៍ចាប់ផ្តើមពីថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ប្រសិនបើសុខភាពរបស់ជនជាប់ចោទមិនអនុញ្ញាតឲ្យស្តាប់សក្ខីកម្ម Elizabeth BECKER[12]។

១១. នៅថ្ងៃដដែលនោះ មន្ត្រីច្បាប់ជាន់ខ្ពស់បានបញ្ជាក់ជូនភាគីថា ដោយសារតែមេធាវីការពារក្តីមួយរូបមានបញ្ហាសុខភាព សវនាការពាក់ព័ន្ធនឹងផលវិបាកនៃសេចក្តីសម្រេចអំពីការបំបែកកិច្ចដំណើរការនីតិវិធីនឹងត្រូវលើកទៅធ្វើនៅថ្ងៃ ច័ន្ទ ទី ១៨ និងថ្ងៃ អង្គារ ទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣[13]។អង្គជំនុំជម្រះបានបញ្ជាក់ថា យោងតាមព័ត៌មានដែលទទួលបាន ទំនងជាមានឱកាសតិចតួចស្តួចស្តើងណាស់ថា លោក នួន ជា អាចចូលរួមក្នុងសវនាការបាន នៅសប្តាហ៍ចាប់ផ្តើមពីថ្ងៃទី ១៨ ខែ កុម្ភៈ និងដោយសារតែភាពមិនច្បាស់លាស់ចំពោះកាលវិភាគបន្តទៀត អង្គជំនុំជម្រះសម្រេចមិនកោះហៅ Elizabeth BECKER មករាជធានីភ្នំពេញទេ។

១២. នៅថ្ងៃដដែលនោះ ប្រហែលពីរម៉ោងក្រោយមក មន្ត្រីច្បាប់របស់អង្គជំនុំជម្រះបានជម្រាបភាគីថា សាក្សីTCW-665 និង TCW-673 នឹងត្រូវកោះហៅឲ្យមកផ្តល់សក្ខីកម្ម នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ក្រោយពីបញ្ចប់សវនាការពាក់ព័ន្ធនឹងផលវិបាកនៃសេចក្តីសម្រេចអំពីការបំបែកកិច្ចដំណើរការនីតិវិធី។

១៣. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ មេធាវីការពារក្តីលោក អៀង សារី បានស្នើសុំឲ្យអង្គជំនុំជម្រះលើកពេលកំណត់ថ្ងៃទី ២២ ខែ កុម្ភៈ ជាកាលបរិច្ឆេទដំបូងដែលតម្រូវឲ្យភាគីរៀបចំសេចក្តីជំទាស់ទៅលើឯកសារថ្មី។ មេធាវីការពារក្តីលោក អៀង សារី យល់ឃើញថាខ្លួនមិនមានលទ្ធភាពរៀបចំសេចក្តីជំទាស់ជាក់លាក់ទៅលើឯកសារនោះទេ ដោយសារតែភាពមិនច្បាស់លាស់នៃវិសាលភាពនៃការជំនុំជម្រះក្តី[14]។

---

[12] ដូចយោងខាងលើ កថាខណ្ឌ ៥។

[13] អ៊ីមែលរបស់លោកស្រី Susan LAMB ផ្ញើជូនភាគី នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៤ និង៤៩ នាទី កម្មវត្ថុ៖ *"ការលើកពេល និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងបែបបទនៃសវនាការស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងបញ្ហាពាក់ព័ន្ធ"*។

[14] អ៊ីមែលរបស់លោកស្រី Pettay ផ្ញើជូនលោកស្រី Susan LAMB នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១០ និង ៣១ នាទី កម្មវត្ថុ៖ *"សំណើសុំពន្យារពេលដាក់សេចក្តីជំទាស់លើឯកសារ"*។

១៤. នៅថ្ងៃដដែលនោះ មន្ត្រីច្បាប់ជាន់ខ្ពស់បានឆ្លើយតបថា អង្គជំនុំជម្រះដឹងច្បាស់អំពីផលវិបាកដែលអាចកើតចេញពីសេចក្ដីសម្រេចអំពីការបំបែកកិច្ចដំណើរការនីតិវិធី ប៉ុន្តែ អង្គជំនុំជម្រះមិនមានបំណងកែប្រែកាលកំណត់ដែលបានប្រកាសរួចទៅហើយនោះទេ[15]។នៅពេលព្រឹក អង្គជំនុំជម្រះបានផ្តល់ចម្លើយតបប្រហាក់ប្រហែលគ្នានេះរួចទៅហើយជូនសហព្រះរាជអាជ្ញា ដែលបានស្នើសុំលើកពេលដាក់បញ្ជីកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ទៅរយៈពេលពីរសប្តាហ៍ ក្រោយពេលអង្គជំនុំជម្រះសម្រេចជាស្ថាពរលើវិសាលភាពនៃការជំនុំជម្រះក្តីកំពុងប្រព្រឹត្តទៅ[16]។

១៥. នៅក្នុងសវនាការថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានប្រកាសអំពីសេចក្តីសម្រេចលើកពេលស្តាប់សក្ខីកម្មសាក្សី TCW-665 និង TCW-673 ទៅថ្ងៃក្រោយ ហើយបានបង្ហាញអំពីចេតនារបស់ខ្លួនក្នុងការមិនធ្វើសវនាការនៅថ្ងៃទី ១៩ ខែ កុម្ភៈ ដូចការគ្រោងទុកពីដំបូង គឺលើកទៅធ្វើនៅថ្ងៃទី ២០ ខែ កុម្ភៈ។

១៦. នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះបានធ្វើជូនភាគីនូវសំណួរបន្ថែម ហើយស្នើឱ្យភាគីឆ្លើយ នៅក្នុងសវនាការថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣[17]។

១៧. នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ មេធាវីការពារក្តីលោក អៀង សារី បានលើកឡើងជាថ្មីម្តងទៀតនូវសំណើសុំពន្យារពេលដាក់សេចក្តីជំទាស់ទៅលើឯកសារថ្មីរបស់សហព្រះរាជអាជ្ញា ខណៈដែលមិនទាន់មានការកំណត់អំពីវិសាលភាពជាក់ច្បាស់នៃការជំនុំជម្រះក្តី[18]។សហព្រះរាជអាជ្ញាបានឆ្លើយតបថា មេធាវីការពារក្តីទាំងបីក្រុមធ្លាប់មានឱកាសក្នុងការជំទាស់លើឯកសារទាំងអស់

---

[15] អ៊ីមែលរបស់លោកស្រី Susan LAMB ផ្ញើជូនលោកស្រី Pettay នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៣ និង ៤០ នាទី កម្មវត្ថុ៖ *"ឆ្លើយតប៖ សំណើសុំពន្យារពេលដាក់សេចក្តីជំទាស់លើឯកសារ"*។

[16] អ៊ីមែលរបស់លោកស្រី Susan LAMB ផ្ញើជូនលោក Smith នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១០ និង ០៤ នាទី កម្មវត្ថុ៖ *"ឆ្លើយតប៖ កំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលសហព្រះរាជអាជ្ញាស្នើសុំដាក់"*។

[17] អ៊ីមែលរបស់លោកស្រី Susan LAMB ផ្ញើជូនភាគី នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៣ និង ៥៧ នាទី កម្មវត្ថុ៖ *"សំណួរបន្ថែមសម្រាប់ភាគី មុនសវនាការស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៅថ្ងៃស្អែក"*។

[18] អ៊ីមែលរបស់លោកស្រី Pettay ផ្ញើជូនលោកស្រី Susan LAMB នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៣ និង ១៧ នាទី កម្មវត្ថុ៖ *"ឆ្លើយតប៖ សំណើសុំពន្យារពេលដាក់សេចក្តីជំទាស់លើឯកសារ"*។

របស់សហព្រះរាជអាជ្ញារួចមកហើយ រួមទាំងឯកសារថ្មីផងដែរ[19]។ ដូចយើងបានឃើញនៅក្នុងកថាខណ្ឌ ២ដល់កថាខណ្ឌ ៤ សហព្រះរាជអាជ្ញាយល់ច្រឡំនូវសេចក្តីណែនាំរបស់អង្គជំនុំជម្រះ និងបង្ហាញឲ្យឃើញនូវអសុទ្ធចិត្តយ៉ាងជាក់ស្តែង។ អង្គជំនុំជម្រះបានលើកពេលសវនាការយ៉ាងច្បាស់ ដោយសារតែហេតុផលយ៉ាងសាមញ្ញបំផុតថាភាគីផ្សេងទៀតមិនអាចពិគ្រោះឯកសារថ្មីភាគច្រើនបាន នៅពេលពិភាក្សាអំពីឯកសារផ្សេងទៀត។ ដូច្នេះ បញ្ហាបីបានចោទឡើង៖ ហេតុអ្វីបានជាសហព្រះរាជអាជ្ញាមិនមានប្រតិកម្មតប តាំងតែពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១២ នៅពេលលោកមេធាវី គង់ សំអុន បានចង្អុលបង្ហាញថាខ្លួនបានយល់អំពីសេចក្តីណែនាំរបស់អង្គជំនុំជម្រះ ហើយមេធាវីការពារក្តីលោក ខៀវ សំផន នឹងលើកឡើងនូវការជំទាស់ទៅលើឯកសារថ្មី តែនៅក្រោយពេលអង្គជំនុំជម្រះកំណត់កាលបរិច្ឆេទមួយសម្រាប់ពិភាក្សាដេញដោលលើបញ្ហានេះ? តើយើងអាចពិភាក្សាអំពីឯកសារថ្មីបានតាមវិធីណា បើយើងមិនអាចពិគ្រោះឯកសារថ្មីទាំងនោះបានផង? ហេតុអ្វីបានជាអង្គជំនុំជម្រះតម្រូវឲ្យភាគីលើកឡើងនូវការជំទាស់ទៅលើឧបសម្ព័ន្ធ ២១ របស់សហព្រះរាជអាជ្ញា ត្រឹមថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ប្រសិនបើការពិភាក្សាដេញដោលបែបនេះពិតបានធ្វើហើយមែននោះ?

១៨. ការផ្លាស់ប្តូរ និងភាពមិនច្បាស់លាស់ទាំងអស់នេះ មានផលប៉ះពាល់យ៉ាងខ្លាំងមិនអាចប្រកែកបានទៅលើការរៀបចំការងាររបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដែលបានលះបង់ពេលវេលាជាច្រើនដើម្បីត្រៀមលក្ខណៈសម្រាប់ការស្តាប់សក្ខីកម្មសាក្សីជំនាញ Elizabeth BECKER អ្នកជំនាញ TCE-65ដែលគ្រោងធ្វើ នៅថ្ងៃទី ០៤ ថ្ងៃទី ០៥ និងថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣ អ្នកជំនាញ TCE-33ដែលគ្រោងធ្វើនៅថ្ងៃទី ២៥ ថ្ងៃទី ២៦ ថ្ងៃទី ២៧ និងថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣ សាក្សី TCW-665 និង TCW-673 ដែលពីដំបូងគ្រោងធ្វើនៅថ្ងៃទី ២០ ខែ កុម្ភៈ ក៏ដូចជាលះបង់ពេលវេលា សម្រាប់ការត្រៀមសវនាការពាក់ព័ន្ធនឹងផលប៉ះពាល់នៃសេចក្តីសម្រេចអំពីការបំបែកកិច្ចដំណើរការនីតិវិធី ហើយទន្ទឹមនឹងនោះ ត្រូវរៀបចំសេចក្តីជំទាស់ទៅលើឯកសារថ្មីរបស់ភាគីទៀត។ ឯកសារទាំងនេះភាគច្រើនមានតែជាភាសាអង់គ្លេស មានចំនួនទំព័រខុសគ្នា ហើយឯកសារខ្លះជាខ្សែវីដេអូទៀត។ នាពេលកន្លងមក មេធាវីការពារក្តីលោក ខៀវ សំផន បានតវ៉ាចំពោះកាលកំណត់ខ្លីពេក ក្នុងការតម្រូវឲ្យខ្លួនរៀបចំសេចក្តីជំទាស់ទៅលើឯកសាររាប់ពាន់

[19] អ៊ីមែលរបស់លោក Smith ផ្ញើជូនលោកស្រី Susan LAMB នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៣ និង ៣៤ នាទី កម្មវត្ថុ៖ *"ចំណងជើងត្រឹមត្រូវនៃអ៊ីមែលគួរតែដាក់ថា៖ ឆ្លើយតប៖ សំណើសុំពន្យារពេលដាក់សេចក្តីជំទាស់លើឯកសារ"*។

ហើយជាចុងក្រោយធ្វើឱ្យមិនអាចមានឱកាសពិភាក្សាដេញដោលតទល់គ្នា[20]។ មេធាវីការពារក្ដីក៏បង្ខំចិត្តធ្វើការជំទាស់ទៅតាមប្រភេទនៃឯកសារ។ អង្គជំនុំជម្រះបានបដិសេធវិធីសាស្ត្រនេះ ហើយបានទទួលយកឯកសារ ដោយសារតែគ្មានការជំទាស់ជាក់លាក់ពីសំណាក់មេធាវីការពារក្ដី[21]។

១៩. ក្នុងល័ក្ខខ័ណ្ឌទាំងនេះ មេធាវីការពារក្ដីលោក ខៀវ សំផន បានខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីបង្ហាញនូវការសង្កេតទៅលើឧបសម្ព័ន្ធ ២១ ប៉ុន្តែ មិនអាចធ្វើបានចំពោះឯកសារទាំងអស់នោះទេ ហើយក៏មិនអាចកំណត់អត្តសញ្ញាណ *"ឯកសារផ្សេងទៀតរបស់ភាគី"* បានដែរ។ មេធាវីការពារក្ដីលោក ខៀវ សំផន សម្ដែងនូវការសោកស្ដាយជាថ្មីម្ដងទៀតចំពោះអវត្តមាននៃឱកាសពិភាក្សាដេញដោលតទល់គ្នាទៅលើភាពអាចទទួលយកបាននៃឯកសារ។

២០. មេធាវីការពារក្ដីលោក ខៀវ សំផន បានចង្អុលបង្ហាញនៅក្នុងឧបសម្ព័ន្ធថាតើឯកសារណាខ្លះដែលខ្លួនមិនមានពេលវេលាពិនិត្យមើលភាពអាចទទួលយកបាន ហើយដែលឯកសារទាំងអស់នេះមិនបានឆ្លងកាត់ការពិភាក្សាដេញដោលតទល់គ្នាទាល់តែសោះ។

## III-ច្បាប់ជាធរមាន

២១. ភាពអាចទទួលយកបាននៃឯកសារថ្មីត្រូវតែពិនិត្យមើលឱ្យបានម៉ត់ចត់ ដោយសារតែវាជាឯកសារដែលមានជាសាធារណៈនិងមានរួចហើយនៅក្នុងដំណាក់កាលស៊ើបអង្កេត ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថាមិនមានភាពពាក់ព័ន្ធគ្រប់គ្រាន់ ដើម្បីបញ្ជាក់ហេតុផលក្នុងការដាក់បញ្ចូលទៅក្នុងសំណុំរឿងស៊ើបអង្កេត។ ក្នុងបរិបទនេះ វិធានដែលអនុវត្តចំពោះភាពអាចទទួលយកបានមានដូចខាងក្រោម។

---

[20] សេចក្ដីជំទាស់មិនទទួលយកបញ្ជីឯកសារ ដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E131/6, សេចក្ដីជំទាស់មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូងទាំងបួន ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ឯកសារ E131/1/11, ប្រតិចារឹកសវនាការ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/28.1 ទំព័រ ៣៣ បន្ទាត់ទី ២ ដល់បន្ទាត់ទី ១៣។

[21] សេចក្ដីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E185 កថាខណ្ឌ ២៣។

២២. ជាដំបូង ឯកសារត្រូវមានជាបីភាសាការងាររបស់ អ.វ.ត.ក។ អង្គជំនុំជម្រះបានចង្អុលបង្ហាញថា *"គ្រប់ឯកសារទាំងអស់ដែលភាគីបានស្នើដាក់ឲ្យពិភាក្សាដេញដោល"* ត្រូវតែមានជាបីភាសានៅត្រឹមថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣។ *"ប្រសិនបើឯកសារដែលស្នើដាក់ឲ្យពិភាក្សាដេញដោលពុំមានទៅតាមលក្ខខណ្ឌតម្រូវ និងមិនទាន់ពេលវេលាកំណត់នោះទេ ឯកសារទាំងនោះមិនអាចចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុងនោះឡើយ"*[22]។

២៣. បន្ទាប់មកទៀត យោងតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចប្រកាសមិនទទួលយកឯកសារភស្តុតាងណាមួយបាន បើយល់ឃើញថា *"ក) មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ) មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ) ច្បាប់មិនអនុញ្ញាត ឬ ង) មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍"*។

២៤. ក្នុងន័យនេះ អង្គជំនុំជម្រះធ្លាប់បានរំឭកថា *"រាល់ឯកសារទាំងឡាយដែលមិនអាចជឿទុកចិត្តបាន (ឬគ្មានយថាភាព) អាចត្រូវបានអង្គជំនុំជម្រះចាត់ទុកថាជាឯកសារមិនអាចបញ្ជាក់អង្គហេតុដែលចង់បង្ហាញ"*[23]។

២៥. ជាចុងក្រោយ ដូចសហព្រះរាជអាជ្ញាបានបញ្ជាក់នៅក្នុងសេចក្ដីជំទាស់របស់ខ្លួនទៅនឹងការកោះហៅសាក្សីរបស់មេធាវីការពារក្ដី យោងតាមវិធាន ៨៧(៣) និងវិធាន ៩៨ នៃវិធានផ្ទៃក្នុង[24]៖

*៩. វិធាន ៩៨ នៃវិធានផ្ទៃក្នុង ដែលកំណត់អំពីបទប្បញ្ញត្តិជាធរមានចំពោះសាលក្រម ចែងនៅក្នុងកថាខណ្ឌ ២ និងកថាខណ្ឌ ៣ ថា "២. សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា*

---

[22] ដូចយោងខាងលើ ឯកសារ E246/1 កថាខណ្ឌ ៣។

[23] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158 អនុស្សរណៈចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ឯកសារ E162 កថាខណ្ឌ ២។

[24] ការជំទាស់របស់សហព្រះរាជអាជ្ញាទៅនឹងសាក្សី និងអ្នកជំនាញ ដែលបានស្នើឡើងដោយភាគីដទៃ ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន ១១ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ ឯកសារ E9/14/1/1 កថាខណ្ឌ ៦។

*ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ(...) ៣. អង្គជំនុំជម្រះត្រូវពិនិត្យថាតើអំពើនោះជាបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងថាតើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរឬទេ"។*

*១០. អង្គហេតុជាសារវ័ន្តត្រូវបានកំណត់ថាជាអង្គហេតុដែលសាលក្រមពឹងផ្អែកលើដោយមិនអាចខ្វះបាន។ ឯកសារមិនពាក់ព័ន្ធនឹងអង្គហេតុជាសារវ័ន្ត ហើយគ្មានតម្លៃជាភ័ស្តុតាង មិនអាចទទួលយកបានឡើយ។ ឯកសារមួយមានតម្លៃជាភ័ស្តុតាងបានប្រសិនបើវាបញ្ជាក់អំពីអង្គហេតុវិវាទ។*

*១១. អាស្រ័យហេតុនេះ ក្នុងការវាយតម្លៃអំពីភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់សាក្សី ឬអ្នកជំនាញណាម្នាក់ អង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់ថា តើសក្ខីកម្មដែលបានស្នើឡើងនោះអាចបញ្ជាក់ ឬមិនអាចបញ្ជាក់ភ័ស្តុតាងនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ឬការចូលរួមរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[25]។*

## IV-**វិនិច្ឆ័យ**

២៦. ឯកសារថ្មីភាគច្រើនរបស់សហព្រះរាជអាជ្ញាប្រាសចាកទាំងស្រុងពីក្របខ័ណ្ឌនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយឯកសារខ្លះបង្ហាញពីអង្គហេតុចេញហួសពីក្របខ័ណ្ឌនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ ឯកសារថ្មីទាំងនេះមិនអាចឱ្យបញ្ជាក់ ឬបដិសេធការប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ ឬការចូលរួមរបស់ជនជាប់ចោទណាម្នាក់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ (ដូចជាឯកសារ E3/705 និង E3/717 ជាដើម)។

២៧. បន្ថែមលើឯកសារមិនមានភាពជាប់ពាក់ព័ន្ធ មេធាវីការពារក្តីសូមលើកឡើងអំពីវត្តមាននៃឯកសារដ៏ច្រើនដែលមិនអាចបញ្ជាក់អង្គហេតុបានដោយសារតែខ្លឹមសារនៃឯកសារទាំងនោះមិនអាចពិនិត្យផ្ទៀងផ្ទាត់បាន ឧទាហរណ៍ ឯកសារដែលមិនមានច្បាប់ដើមជាភាសាខ្មែរ ឯកសារដែលលើកឡើងអំពីសម្តីខុសបរិបទ រូបថតដែលមិនមានចុះកាលបរិច្ឆេទ និង/ឬ មិនអាចកំណត់អត្តសញ្ញាណអ្នកថតរូបបាន ឬឯកសារដែលមិនដឹងប្រភព។

[25] ដូចយោងខាងលើ ឯកសារ E9/14/1/1 កថាខណ្ឌ ៩ ដល់កថាខណ្ឌ ១១ (ដកកំណត់សម្គាល់ជើងទំព័រចេញ)។

២៨. ឯកសារផ្សេងទៀតមិនមានយថាភាព ហើយនាំឲ្យមានការអត្ថាធិប្បាយខុស ឧទាហរណ៍ អត្ថបទសារព័ត៌មាន *វ៉ាស៊ីនតោនប៉ុស្តិ៍*(E190.1.327ឯកសារលេខរៀង ៩៧ នៃឧបសម្ព័ន្ធ ២១)ចុះផ្សាយថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៧៧ ដែលអត្ថាធិប្បាយអំពី *"រូបថតមួយឈុត ដែលជារូបថតដំបូងៗបង្ហាញពីលក្ខខណ្ឌការងារដោយបង្ខំនៅតាមជនបទនៃប្រទេសកម្ពុជា ទៅដល់បស្ចិមប្រទេស"*[26]។ តាមពិត ដូចលោក Noam Chomsky[27] បានលាតត្រដាង រូបថតទាំងនេះទំនងមិនមែនត្រូវបានថតនៅកម្ពុជាប្រជាធិបតេយ្យនោះទេ ប្រហែលជាថតនៅកន្លែងផ្សេង នៅសម័យកាលផ្សេង។ មេធាវីការពារក្តីលោក ខៀវ សំផន សូមលើកយកមតិរបស់លោក Noam Chomsky មកជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារនេះ។ គួរកត់សម្គាល់ត្រង់ចំណុចនេះថា មេធាវីការពារក្តីលោក ខៀវ សំផន បានស្នើសុំកោះហៅអ្នកនិពន្ធរូបនេះឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ[28] ប៉ុន្តែ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើនេះ[29]។

២៩. មេធាវីការពារក្តី មិនមែនជាអ្នកត្រូវបង្ហាញអំពីកង្វះយថាភាពនៃឯកសាររបស់សហព្រះរាជអាជ្ញានោះទេ គឺសហព្រះរាជអាជ្ញាជាអ្នកបង្ហាញអំពីភាពអាចជឿទុកចិត្តបាននៃឯកសារ ដែលខ្លួនចង់យកមកប្រើដើម្បីដាក់បន្ទុកជនជាប់ចោទ ជាជាងការពន្លិចពន្លង់អង្គជំនុំជម្រះទៅក្នុងគំនរឯកសារដ៏ច្រើនសម្បើម ដែលភាពពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន អាចត្រូវបានជំទាស់តវ៉ា។ត្រឹមតែបង្ហាញថាអត្ថបទសារព័ត៌មានជាអត្ថបទមានយថាភាព មិនគ្រប់គ្រាន់នោះទេ។ ក៏ប៉ុន្តែ ប្រសិនបើសហព្រះរាជអាជ្ញាមិនមានចេតនាប្រើប្រាស់ខ្លឹមសារនៃអត្ថបទសារព័ត៌មាននោះទេ គឺចង់បង្ហាញអំពីបរិយាកាសប្រឆាំងខ្មែរក្រហម ដែលផ្សព្វផ្សាយបន្តដោយអ្នកសារព័ត៌មានបស្ចិមប្រទេស និង

[26] *ពលកម្មដោយបង្ខំក្នុងប្រទេសកម្ពុជា* អត្ថបទនិពន្ធដោយ Ann Mariano សម្រាប់ Washington Post ឯកសារ E190.1.327 ទំព័រ ១។

[27] *After the Cataclysm : Postwar IndoChina and the reconstruction of imperial ideology*, The political economy of Human Rights ភាគ ២ Noam Chomsky និងEdward S. Herman ឆ្នាំ១៩៧៩ ទំព័រ ១៦៩ ដល់ ១៧១ អាចរកបានលើគេហទំព័រ៖

« http://books.google.fr/books?id=EH00v6lNzb4C&printsec=frontcover&dq=chomsky+after+the+cataclysm&hl=fr&sa=X&ei=NoElUfvKBJOEhQfbyICABw&ved=0CDQQ6AEwAA#v=onepage&q=chomsky%20after%20the%20cataclysm&f=false. »

[28] បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលស្នើសុំឲ្យកោះហៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/6.2 ទំព័រ ១។

[29] ឧបសម្ព័ន្ធ ខ នៃសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញាទៅនឹងការកោះហៅសាក្សី និងអ្នកជំនាញមួយចំនួន ដែលស្នើដោយភាគីផ្សេងទៀត ឯកសារ E9/14/1/1.12 ទំព័រ ១៦។

បរិបទប្រឆាំងកុម្មុយនីស្តដែលមាននៅសម័យសង្គ្រាមត្រជាក់នោះ មេធាវីការពារក្តីមិនជំទាស់ទៅនឹងការប្រកាសទទួលយកឯកសារទាំងនេះទេ។

៣០. ជាចុងក្រោយ ឯកសារផ្សេងទៀតត្រូវតែបដិសេធចោល ដោយហេតុថាឯកសារទាំនេះត្រូវបានច្បាប់ហាមឃាត់ ឧទាហរណ៍ ឯកសារបានមកពីការស៊ើបអង្កេតក្រៅក្របខ័ណ្ឌតុលាការ ដែលត្រូវធ្វើមោឃភាព ប្រសិនបើការស៊ើបអង្កេតត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងល័ក្ខខ័ណ្ឌស្រដៀងគ្នាឯកសារទាញសេចក្តីសន្និដ្ឋានចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទ ដោយផ្អែកលើឯកសារដែលមិនអាចយកមកធ្វើជាមូលដ្ឋានតាមផ្លូវច្បាប់សម្រាប់ការផ្តន្ទាទោសនៅចំពោះមុខ អ.វ.ត.ក (ឧទាហរណ៍ ឯកសារដែលទទួលបានដោយសារការធ្វើទារុណកម្ម ឬឯកសារដែលមិនមាននៅក្នុងសំណុំរឿងស៊ើបអង្កេត ដូចជា ឯកសារ E190.1.402 ជាដើម)។

៣១. មេធាវីការពារក្តីបង្ហាញនូវទឡ្ហីករណ៍លម្អិតជាក់លាក់ចំពោះឯកសារនីមួយ នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីជំទាស់នេះ។

៣២. មេធាវីការពារក្តីលោក ខៀវ សំផន បង្ខំចិត្តដាក់សេចក្តីជំទាស់នេះជាភាសាបារាំងសិន បន្ទាប់ពីទទួលបានព័ត៌មានថា មន្ត្រីពិនិត្យ-ផ្ទៀងផ្ទាត់ការបកប្រែពីភាសាបារាំងទៅខ្មែរកំពុងឈប់សម្រាកប្រចាំឆ្នាំ ហើយអ្នកបកប្រែជាប់រវល់បកប្រែឯកសារដែលស្នើសុំដោយភាគីផ្សេងទៀត[30]។

៣៣. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **សម្រេច និងប្រកាស** ថា លោក ខៀវ សំផន មិនមានឱកាសពិភាក្សាដេញដោលតទល់ទៅលើឯកសារថ្មីទាំងអស់របស់ភាគីនោះទេ។
- **សម្រេច និងប្រកាស**ថា ឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធនៃសេចក្តីជំទាស់នេះ មិនអាចទទួលយកបាន។

---

[30] អ៊ីមែលរបស់លោក គាំ ច័ន្ទមុន្នី ផ្ញើជូនមេធាវីការពារក្តីលោក ខៀវ សំផន នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១១ និង ៣៩ នាទី កម្មវត្ថុ៖ *"ឆ្លើយតប៖ សំណើសុំបកប្រែ"*, អ៊ីមែលពី *« Translation Admin »* ផ្ញើជូនមេធាវីការពារក្តីលោក ខៀវ សំផន នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៥ និង ១៦ នាទី កម្មវត្ថុ៖ *"អង្គភាពបកប្រែភាសាប្តូរកាលបរិច្ឆេទថ្មីនៃការប្រគល់ឯកសារបកប្រែ"*។

- ដកលេខសម្គាល់ E3 ចេញពីឯកសារមិនមានភាពពាក់ព័ន្ធ ដូចជា ឯកសារ E3/717, E3/705 ជាដើម។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងភ្នំពេញ | |
| | មេធាវី Jacques VERGÈS | ទីក្រុងប៉ារីស | |